# ពីជ័យជេដ្ឋាទី៤ មកនរោត្តម-សីហនុ

# ស្តេចដាក់រាជ្យ ជាកាំបិតចិតជងឯង!

ដោយ សុទ្ធ-បូលិន ★ ថ្ងៃទី៥ វិច្ឆិកា ២០០៤

ក្នុងពង្សាវតាកម្ពុជា វត្តមាននៃស្តេចដាក់រាជ្យ ដែលបណ្តាលឲ្យព្រះរាជាណាចក្រស្គាល់ការក្រឡាប់ចាក់ភ័ន្តប្រែនោះ នៅមានច្រើនអង្គទៀតណាស់ ។ ក្នុងប្រការនេះ ព្រះអង្គស្ងួរ (ព្រះជ័យជេដ្ឋាទី៤) មានលក្ខណ: ដូចស្តេចសីហនុច្រើនជាងគេទាំងអស់ (ទំនងមើលទៅ ព្រឹត្តិការណ៍នៅក្នុងព្រះរាជវាំងខ្មែរ ស្រដៀងៗគ្នាបានកើតឡើងរបៀបដដែលៗ ពីសតវត្សមួយទៅសតវត្សមួយ ដែលធ្វើឲ្យយើងពិបាកសំរេចថា ជាចំណារព្រហ្មលិខិតនោះពេកណាស់... បើនិយាយថាជាចំណាររបស់ជនជាតិយួននោះវិញ ទើបសមជាង) ។

យើងបិតនៅប្រទេសកម្ពុជានៃគ.ស.១៦៧៥ ពោលពី៤៧ឆ្នាំក្រោយមក បន្ទាប់ពីស្តេចជ័យជេដ្ឋាទី២ ដែលបានទទួលយកកូនស្តេចយួន កូជិនស៊ិន មកធ្វើជាប្រពន្ធចុង ចូលមរណកាលទៅ ។ គឺនៅក្នុងកាលសម័យមួយ ដែលយួនបានវាតយកទឹកដីកម្ពុជាក្រោម អស់ជាងពាក់កណ្តាលទៅហើយ ដោយបានប្រើមធ្យោបាយបំបែកបំបាក់ផ្ទៃក្នុងនៃវាំងខ្មែរ ឲ្យកើតមានសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ក្នុងប្រការឲ្យខ្មែរសម្លាប់គ្នាឯងអស់ទៅ យួនវាតដីចូលមកតាំងនៅដោយមិនបាច់ប្រឹង ដោយស្របនឹង «ចំណារព្រហ្មលិខិត» ដែលយួនបានតាក់តែង ។ ជាការពិតណាស់ គ្រាន់តែព្រះជ័យជេដ្ឋាទី២សុគតភ្លាមកាលណា ព្រះរាជបុត្រច្បងរបស់ព្រះអង្គ ព្រះស្រីធម្មោរាជា ហៅព្រះរាជសម្ភារ ក៏ឡើងគ្រងរាជ្យ...។ ក៏ប៉ុន្តែស្តេចអង្គនេះ បានទៅសាងផ្នួសមួយរំពេជ ដោយពុំដឹងបុព្វហេតុអ្វីច្បាស់លាស់ (គឺដូចដាក់រាជ្យអញ្ចឹងដែរ) ដោយប្រគល់កិច្ចការនគរឲ្យស្តេចមាគឺព្រះឧទ័យមហាឧបរាជ ទទួលមើលការខុសត្រូវ ។ មហាឧបរាជឆ្លៀតឱកាសរៀបអាពាហ)ពិពាហ៍ជាមួយនឹងគូដណ្តឹងស្រស់ក្មេងរបស់ព្រះរាជសម្ភារ... ព្រះអង្គវត្តី ។ លុះព្រះរាជសម្ភារវិលត្រឡប់មកកាន់ព្រះរាជបល្ល័ង្ក ទ្រង់ក៏បានឆក់ដណ្តើមយកព្រះនាងអង្គវត្តីទៅវិញ ដូចតែព្រះរាមឆក់យកព្រះនាងសីតាពីក្រុងរាពណ៍... បណ្តាលឲ្យកើតចំបាំងរាំងជល់ វឹកវរ ស្លាប់អស់រាស្ត្រប្រជាជាច្រើនម៉ឺនសែននាក់ នៅតំបន់ខាងកើត ។ (តើមានរឿងហេតុអ្វី ដែលឆ្កែចចកយួនមិនចូលមកយ៉ាងស្រួលវាតដីតាំងនៅក្នុងស្រុកខ្មែរ ដែលអស់ព្រំដែនទៅហើយនោះ) ។

**គ.ស.១៦៧៥** ៖ ព្រះអង្គស្ងួរ ឬជ័យជេដ្ឋាទី៤ ទើបឡើងសោយរាជ្យនៅឆ្នាំនោះឯង ក្នុងជន្មាយុ១៩ឆ្នាំ (ដូចស្តេចសីហនុនៅក្នុងសតវត្សទី២០) ។ ស្តេចអង្គនេះបានដាក់រាជ្យបួនដង... ហើយក៏ដូចព្រះអង្គសីហនុ ទ្រង់ជាកត្តាមួយធំនៃការរលត់រលាយប្រទេសកម្ពុជា, នៃការបែកបាក់និងសង្គ្រាមស៊ីវិល ដោយហេតុថា នៅពេលណាដែលទ្រង់សំរេចថាត្រឡប់មកសោយរាជ្យសាជាថ្មីវិញ ទ្រង់បានបង្កើតក្រុមសត្រូវនៅក្នុងរូបស្តេចដែលបានបាត់បង់រាជបល្ល័ង្កទៅ ឬនៅក្នុងក្រុមបក្សពួកអ្នកគាំទ្រស្តេចក្រោយនេះ ។

**គ.ស.១៦៨៨** ៖ ព្រះអង្គស្ងួរ អាយុ៣១ឆ្នាំ ប្រហែលគ្នានឹងជន្មាយុរបស់ស្តេចសីហនុ ពេលឡើងប្រមុខរដ្ឋនៅក្នុងឆ្នាំ១៩៦០ ។ ទ្រង់មានប្រជាប្រិយភាពជាខ្លាំង ព្រោះទើបនឹងបានឈ្នះសង្គ្រាមជាមួយនឹងព្រះអង្គម្ចាស់អង្គនន់ (បងជីដូនមួយរបស់ស្តេច) ដែលបានទៅកេណ្ឌជនជាតិយួននិងចិន ពីកម្ពុជាក្រោមមកវាយប្រហារខ្មែរកណ្តាល ។ (ថ្វីបើកាល:ទេស:ខុសគ្នាមែនពិត ក៏ប៉ុន្តែប្រជាប្រិយភាពរបស់ព្រះអង្គស្ងួរកាលសម័យនោះ ក៏មិនសូវខុសគ្នាពីប្រជាប្រិយភាពរបស់ស្តេចសីហនុកាលសម័យសង្គមរាស្ត្រនិយមនោះដែរ... ស្តេចមួយបានច្បាំងឈ្នះចិនយួន ស្តេចមួយទៀតទាមទារឯករាជ្យពីបារាំងអាណានិគម... ប៉ុន្តែនៅពេលដែលស្តេចទាំងពីរ បានទទួលជោគជ័យពេញទំហឹង ក៏ស្រាប់តែបានទទួលបរាជ័យផងដែរ ដោយត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមទាំងស្រុង ។ ទឹកដីកម្ពុជាក្រោមបានធ្លាក់ទៅក្នុងកណ្តាប់ដៃយួនជាផ្លូវការ ក្រោមរាជ្យស្តេចសីហនុកាលពីឆ្នាំ១៩៤៩ ។

ព្រះអង្គស្ងួរ ហៅជ័យជេដ្ឋាទី៤ ដើម្បីរំឭកគុណបុណ្យព្រះពុទ្ធសាសនា ដែលបានជួយទ្រង់ឲ្យរួចរស់ជីវិតនៅក្នុងពេលអាសន្នអន់ក្រ ក៏បានសំរេចកសាងវត្តជាច្រើន នៅចន្លោះជ្រោយចង្វារនិងឧដ្ដុង្គ ។ ជាមួយម្តាយមីងរបស់ទ្រង់ម្នាក់ឈ្មោះសម្តេចព្រះទាវ អាយុ១៥ឆ្នាំ... ព្រះមហាក្សត្រក៏យាងទៅសាងព្រះផ្នួសនៅវត្តព្រៃពួន ដែលចៅពញាភុក បានបញ្ជាឲ្យជីកស្រះស្រង់ជាទីមនោរម្យក្រៃលែងនៅជុំវិញនោះ ។

ការដែលស្តេចត្រូវបួសជាព្រះសង្ឃ ជាមួយម្តាយមីងក្មេងជាដូនជីក្នុងគោល ប្រាថ្នាឡើងទៅឋានសួគ៌៧ជាន់ទាំងពីរនាក់ នៅក្នុងក្របខ័ណ្ឌនៃលទ្ធិព្រះពុទ្ធសាសនា បានប្រព្រឹត្តទៅអស់បីខែ (ថ្ងៃក្រោយមក, ១៩៤៧, ពេលស្តេចសីហនុទៅសាងផ្នួសនៅវត្តសារាវ័ន្ត...ទ្រង់ក៏បានយកម្ចាស់ក្សត្រីស៊ីសុវត្ថិ-ពង្សានមណី ហៅម្ចាស់ម៉ោង ជាម្តាយមីងក្មេងទៅ «ឃិត» ដូចគ្នាបេះបិទ) ។ នៅពេលនោះ ពាក្យចចាមអារាមមិនល្អសំរាប់ស្តេច ក៏បានត្រូវផ្សព្វផ្សាយខ្ចរខ្ចាយពេញទាំងផ្ទៃប្រទេស ។ អ្នកផងបានអះអាងថា ដែលព្រះអង្គស្ងួរមានការជាប់ចិត្តជាប់ថ្លើម ជាមួយម្តាយមីងខ្លួនឯងដល់ថ្នាក់នេះ គឺបណ្តាលមកពីសម្តេចព្រះទាវនោះ ជាសាហាយស្មន់របស់ទ្រង់ ។ ព្ធដូច្នេះ ម្ចាស់ក្សត្រីក្មេងអង្គនេះ ដែលទើបតែបោះបង់សំលៀកបំពាក់ជាដូនជី ក៏មានកំហឹងឆាបឆ្អួលជាខ្លាំង ។ ទ្រង់ក៏បានដាក់បណ្តាសារទាំងក្រេវក្រោធ ចំពោះជនណាដែលបាននិយាយអាក្រក់ពីទ្រង់ ដោយបោះពាក្យសំដីជាឧឡាបុកដូច្នេះថា ៖ «ជនណាក៏ដោយ ទោះជាមានបុណ្យស័ក្តិជាមន្ត្រី ខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ, ឬក៏ជារាស្ត្រប្រជាក៏ដោយ, ដែលបានបង្កើតឲ្យមានមន្ទិលសៅហ្មងចំពោះសកម្មភាពរបស់ខ្ញុំ ជនណាក៏ដោយ ដែលបាននិយាយហែកកេរ្តិ៍អាក្រក់ពីអតីតកាលរបស់ខ្ញុំ សូមឲ្យជននោះស្លាប់តែហោងដោយវត្ថុស័ក្តិសិទ្ធិ...ហើយសូមឲ្យព្រះពុទ្ធក្នុងអនាគតកាល-ព្រះសិអារមេត្រី កុំឲ្យជួយប្រោសល្មួសពួកទាំងនោះឲ្យសោះ» (ស្រង់ចេញពី **Histoire du Cambodge, par Adhémarc Leclère**) ។

ព្រះអង្គស្ងួរបានដាក់រាជ្យ៤ដង ហើយនៅពេលដែលទ្រង់សុគតទៅ (គ.ស.១៧០២) ស្តេចខ្មែរដែលសោយរាជ្យក្រោយទ្រង់ មានបូរណភាពទឹកដីតែត្រឹមភ្នំពេញ ជ្រោយចង្វារ ហើយនិងឧដ្ដុង្គ...។ លុះដល់រាជ្យព្រះអង្គម៉ី (គ.ស.១៨៣៤-១៨៤១ សម័យទ្រឿង-មិញយ៉ាំង)ស្តេចខ្មែរក៏ត្រូវបាត់បង់ទឹកដីជ្រោយចង្វារនោះថែមទៅទៀត ។

**គ.ស.១៩៦០** ៖ ខ្ញុំបានយកឆ្នាំ១៩៦០ ឬឆ្នាំដែលព្រះករុណាព្រះបាទសុរាម្រិតទ្រង់ចូលទីវង្គត មកធ្វើជាព្រំដែនឬខណ្ឌសីមានៃ «ព្រឹត្តិកា

រណ៍១៨មិនាឆ៩ ៧០» ដែលជាថ្ងៃស្លាប់នៃសករាជមួយ, នៃរាជវង្សមួយ
ក្នុងដំណើរវិវឌ្ឍន៍ដែលចៀសមិនរួច ទៅរកការរលាយរលត់ខ្លួនឯង តាំ
ង់តែពីសម័យអង្គរដ៏មហារុងរឿង រហូតមកដល់សម័យទំនើបថ្មី ។ ខ្ញុំបា
នយក«ខ័ណ្ឌសីមានៃពេលវេលា»នេះ, គ.ស១៩៦០... មកប្រើសំរាប់ប-
ង្វិតចុះឡើង រុញទៅអតីតកាល ឬទៅអនាគតកាល តាមសេចក្តីតម្រូវនៃ
នៃការចាំបាច់ ដោយហេតុថាកាលសម័យនោះ សម្តេចសីហនុឧបយុ
វរាជ បានក្លាយទៅជាមហាឧបរាជសម័យទំនើប មានប្រជាប្រិយភាពដ-
ល់កំពូល នៃជីវិតនយោបាយរបស់ទ្រង់ទៅហើយ ។

ប្រជាប្រិយភាព ឬសេចក្តីស្នេហាផ្តាប់មុខរបស់ប្រជាជាតិមួយទាំង
មូលចំពោះបុគ្គលម្នាក់ ត្រូវចាត់ទុកជាគុណសម្បត្តិល្អដ៏ធំក៏បាន ដូចជាភ្នំ
មាសអីចឹង... ត្រូវចាត់ទុកថាជាថ្នាំពុលក៏បានដែរ, ៖ ដោយសម្តេចសីហនុ
ហ៊ានធ្វើ ហើយអាចធ្វើរបស់តែមួយគត់ ដែលគ្មានមនុស្សណាម្នាក់ទៀត
មានសមត្ថភាពនឹងធ្វើបាន ឬក៏នឹកស្មានបាន... ដើម្បីប្រឆាំងនឹងរាជានិ-
យមខ្មែរ, ប្រឆាំងនឹងរាជវង្សានុវង្សរបស់ខ្លួនឯង គឺទុករាជបល្ល័ង្កខ្មែរ
និងស្វេតឆ័ត្រនៃវាំងខ្មែរ ឲ្យនៅទំនេរគ្មាននរណាកាន់កាប់ ដោយព្រះអង្គ
ត្រូវការតែងតាំងខ្លួនឯងជា «រាស្ត្រស្តេច» ឬ «ស្តេចរាស្ត្រ» មានឋានៈដូ
ចជាប្រធានាធិបតី ដែលកាន់អំណាចក្នុងសាធារណរដ្ឋដូច្នោះឯង ពោល
ធ្វើស្តេចដោយមិនបាច់សោយរាជ្យ ។ ម្ល៉ោះហើយឆ្នាំ១៩៦០ គឺជាដើមកំ-
ណើតនៃវិបត្តិរបបរាជានិយម មានលំនាំដូចជាចំណុចតូចមួយ ធ្លាក់សំ-
យុងពីលើមេឃ ហើយក្លាយទៅជាមហាឥន្ទ្រីខ្មៅមួយ ដែលថ្ងៃក្រោយ
ទៅស្រូបយកព្រលឹងខ្មែរអស់រាប់លាននាក់... ព្រោះវាបណ្តាលឲ្យមានជា
ចុងចប់ ជាទឹកទីបង្ហើយនូវ «ព្រឹត្តិការណ៍ ១៨មិនា១៩៧០» ដែលទំនងដូ
ចជាថ្ងៃអវសាន្តនៃរាជានិយមពូជត្រសក់ផ្អែម ។

នៅឆ្នាំ១៩៦០... ឬឆ្នាំរលត់វិញ្ញាណនៃ «ព្រះកាញ្ចនកោដិ» ព្រះបាទ
សុរាម្រិត ឬឆ្នាំវិបត្តិវាំងដ៏មហិមា ឆ្នាំនៃការបំផ្លាញរាជានិយមខ្មែរ ដោយ
សារព្រះហត្ថអង្គឯង នៃសម្តេចសីហនុឧបយុវរាជ មានមន្ត្រីជាន់ខ្ពស់ជា
ច្រើនបានស្នើសុំឲ្យ«ព្រះមហាឧបរាជ» ឬសម្តេចព្រះឧបយុវរាជ អង្គពោ
ធិសត្វនោះ ប្រគល់ព្រះរាជបល្ល័ង្កទាំងស្រុងតែម្តង ទៅព្រះមហាក្សត្រី
យានីកុសុមៈនារីរ័ត្ន ដែលជាវីរក្សត្រីមួយនឹងនរ មានវិចារណញ្ញាណខ្ពង់
ខ្ពស់ផ្នែកនយោបាយ ដែលឥស្សរជនដ៏មានតម្លៃជាច្រើនទុកព្រះអង្គជា
សក្ការៈបូជា... មានជាអាទិលោកស៊ឹម-វ៉ារ, លោកផូ-ព្រឿង, លោកសឺន
សាន, លោកសាន-យុន ។ល។ ក្នុងគោលបំណងឲ្យមានស្ថិរភាពនយោ
បាយចំពោះប្រទេសជាតិ ។

លោកសឺន-សានជាពិសេស ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រីទី១
និងជារដ្ឋម-ន្ត្រីការបរទេសរបស់សង្គមរាស្ត្រនិយម បានស្នើសុំឲ្យរដ្ឋស
ភានិងក្រុមប្រឹក្សាព្រះរាជាណាចក្រ ធ្វើការកែប្រែមាត្រា២៥ដែលចែងថា
«មានតែកូនចៅប្រុសនៃស្តេចអង្គដួងតែប៉ុណ្ណោះទេ ដែលមានលទ្ធភាព
ភាពឡើងសោយរាជ្យជាម្ចាស់ផែនដី ប៉ុន្តែសម្តេចព្រះឧបយុវរាជទ្រង់មិ
នយល់ព្រម ដោយទ្រង់យកលេសថា ទ្រង់មិនចង់ឲ្យក្រុមគ្រួសារលោក
ផ្ទាល់ មានម្តាយនិងកូនរបស់ទ្រង់ ទទួលកាន់កាប់រាជសម្បត្តិ នៃវាំងស្តេ
ចខ្មែរ ។ តាមពិតគ្រួសារមិនផ្ទាល់របស់សម្តេច ក៏សម្តេចមិនព្រមប្រគ
ល់ទៅឲ្យគេដែរ ដូចជាសម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីរេត ។

តាមពិតព្រះឧបយុវរាជអ្នកមានបុណ្យ ឬ «ព្រះពោធិសត្វ» ដែល
ហោះហើរតាមឧទ្ធម្ភាគចក្រ ឬ «ព្រះធម្មិកខ្មែរសីអារមេត្រី» បែរជាសុខ
ចិត្តឲ្យគេថែមថយប៊ីចេង ដាក់នៅក្នុងរដ្ឋធម្មនុញ្ញទៅវិញ ជាពិសេសវាយ
ស្នៀតបញ្ចូលមាត្រា១២២ (ឬមាត្រា០០៤... អាចោររួចខ្លួន ម្ចាស់ជាប់គុក)
ដែលបញ្ជាក់ថា ៖ «សភាទាំងពីរនៃព្រះរាជាណាចក្រខ្មែរ ក្នុងការប្រជុំ
រួមគ្នាជាមហាសន្និបាត អាចមូលមតិគ្នាជាឯកច្ឆន្ទ តែងតាំងវរជនដ៏ខ្ពង់ខ្ព
ស់កំពូលម្នាក់ ដែលគ្មាននរណាអាចប្រកែកបាន - **Une personnalité
incontestée** ស្របតាមឆន្ទៈនៃប្រជានុរាស្ត្រ ឲ្យមានតំណែងជាប្រមុខ
រដ្ឋ»... ដើម្បីទ្រង់មានលទ្ធភាពអោបក្រសោបអំណាចជាស្តេចផងនិងជា
រដ្ឋមន្ត្រីទី១ផង... រីឯព្រះមហាក្សត្រីយានីវិញ ក្លាយទៅជាស្តេចស្រីមួយ
ដែលល្អួចកៅអីគេអង្គុយ... ស្តេចឥតច្បាប់ក្នុងវាំង ឥតមានរនាំងការពារ
ប្រហែលគ្នានឹងខ្យងឥតសំបក ឬអណ្តើកឥតស្នូក គ្មាន«ក្រដាស់ស្នាម»
អ្វីទាំងអស់... គ្មាន«អេតាស៊ីវិល» គ្មានមាត្រាចែងក្នុងរដ្ឋធម្មនុញ្ញ ចង់គេ
ដេញចោលនៅម៉ោងណាក៏បាន ដូចឈ្នួលបំរើ ។ គឺជាថ្ងៃចាប់ផ្តើមនៃទំ-
នាស់ដ៏ធ្ងន់ធ្ងរ រវាងស្តេចម៉ែនិងស្តេចកូន ដោយសារតែមុន នឹងមាន«អំ
ពើក្បត់រាជានិយមនៃថ្ងៃ១៨មិនា១៩៧០ ពីសំណាក់លោកលន់-នល់,
សិរិមតៈ, អ៊ិន-តាំ និងចេង-ហេង» គឺវាមានរដ្ឋប្រហារប្រឆាំងនឹងរាជប-
ល្ល័ង្កម្តងរួច ទៅហើយនៅឆ្នាំ១៩៦០... ជាស្នាដៃដ៏ឆ្នើមរបស់សម្តេចនរោ
ត្តម-សីហនុឧបយុវរាជនោះឯង ។ លោកសឺន-សាន ដោយមានទោម-
នស្សជាខ្លាំងជាមួយនឹងសម្តេចព្រះឧបយុវរាជ ក៏បានដើរចាកចេញពេ-
លនោះ ពីរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយមម្តងរួចទៅហើយ ។

មាត្រារដ្ឋធម្មនុញ្ញ១២២ខាងលើនេះ គឺជា«កាំបិតចិតដងឯង»ពីព្រោះ
បានលើកព្រះឧបយុវរាជ (ស្តេចដែលបានដាក់រាជ្យ) ឲ្យឡើងកាន់អំណា
ចជាប្រមុខរដ្ឋ រហូតដល់លុបបំបាត់វត្តមាននៃព្រះមហាក្សត្រគ្រងរាជ្យ ។
ប៉ុន្តែគឺមាត្រាដដែលនេះឯង ដែលតម្រូវឲ្យ«កាត់ក្បាល»ព្រះឧបយុវរាជ
វិញ (តាមផ្លូវនយោបាយ) នៅថ្ងៃទី១៨មិនា១៩៧០ក្រោយមក ។ នៅពេ-
លដែលរាស្ត្រប្រជាងើបឡើងបះបោរប្រឆាំងនឹងវត្តមានយៀកកុង-យៀ
កណាមខាងជើងនៅក្នុងទឹកដីខ្មែរ ព្រមទាំងប្រឆាំង«វរជន» ដែលបាន
អនុញ្ញាតឲ្យមានវត្តមាននេះ ពោលគឺសម្តេចសីហនុ, សភាទាំងពីរដែល
មានការគាំទ្រពីរដ្ឋាភិបាលលន់នល់-សិរិមតៈ បានមូលមតិជាឯកច្ឆន្ទ
ដកតំណែងពីសម្តេចព្រះប្រមុខរដ្ឋវិញ (ខ្វះតែសម្លេង២នាក់ប៉ុណ្ណោះដែ-
លគាំទ្រសម្តេច គឺលោកគីម-ផុន និងលោកសុស-សាអុន ដែលការ
ចំអកនៃព្រេងវាសនា បណ្តាលឲ្យខ្មែរយៀកមិញដែលកាន់ជើងសម្តេច
ហែកទ្រូងរូងថ្លើមប្រមាត់នៅទីក្រុងកំពង់ចាម) ។ បើសភាទាំងពីរជាប្រ-
ភពនៃអំណាចប្រមុខរដ្ឋកាលក្នុងឆ្នាំ១៩៦០... សភាដដែលក៏មានអំណាច
ដកមុខតំណែងនេះទៅវិញដែរ នៅក្នុងឆ្នាំ១៩៧០ ។ ដូច្នេះហើយបានជា
យើងអាចនិយាយបានថា រដ្ឋប្រហារលន់នល់-សិរិមតៈ, ចេង-ហេង, អ៊ិ
ន-តាំ នៃថ្ងៃទី១៨មិនា១៩៧០ គឺជារដ្ឋប្រហារដ៏ចម្លែកមួយ ព្រោះជារដ្ឋប្រ
ហារត្រឹមត្រូវតាមច្បាប់ ។

★★★ យោងតាមពន្លឺដែលផ្តល់មកពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំង
អស់ខាងលើនេះ ខ្ញុំអាចមើលឃើញក្រឡាសម្ងាត់ខ្លះៗរបស់ជនជាតិយួ-
ន ដែលបានលូកដៃកកូរបញ្ហាផ្ទៃក្នុងនៃព្រះរាជវាំងខ្មែរ ។ ពីព្រះជ័យជេ-
ដ្ឋាទី២ដែលបាន«រួមរ័ត»ជាមួយនឹងព្រះនាងកូជិនស៊ិន មកព្រះរាជសម្ភារ
ដែលបាន«រួមរ័ត»ជាមួយនឹងព្រះអង្គវត្តី, ពីជ័យជេដ្ឋាទី៤ ដែលបាន«រួម
រ័ត»ជាមួយសម្តេចព្រះទាវ (ទេវី) មកដល់ស្តេចសីហនុ (ជ័យជេដ្ឋាទី៧)
ដែលបាន«រួមរ័ត»ជាមួយអ្នកម្នាងម៉ូនិក... យួនតែងបាន «ដាក់អំពើ»ឲ្យ
ស្តេចធ្លាក់ឆ្កួតលីលើ ដោយពួកភ្នាក់ងារយួនបង្កប់ខ្លួនក្នុងព្រះរាជវាំង
នោះឯង ។ យួន«ទាញខ្សែញាក់» ឲ្យមហាក្សត្រអាយ៉ងឬទីងមោងរបស់
វៀតណាមឈ្លក់នឹងកាមតណ្ហា, អស់ពីរត់ទៅកសាងព្រះផ្នួស ក៏វិលត្រ-
ឡប់មកលួចប្រពន្ធគេ, ឲ្យ«មោហ៍បាំងជញ្ជាំងបិទ» បើរួមរ័តជាមួយម្តាយ
មីងខ្លួនឯង នៅក្នុងបរមរាជវាំង វាគ្មានអ្វីគួរអស្ចារ្យសោះ... ក៏ប៉ុន្តែបើបា
ន«ធឹងមោង» គ្នា (ភាសារបស់សម្តេចសីហនុ) នៅក្នុងកុដិនៃព្រះសម-
ណគោត្តម... នោះប្រសើរណាស់ ! ព្រះអង្គទាំង២ អាចយាងបោះពួយ

ទៅស្ថានតុសិត ដើម្បី«គៀងទាអាឡេវ» ។ ក្នុងគ្រាប់គ្រួសតែមួយ យួនបាញ់បានចាបពីរ គឺបានសម្លាប់នហាក្សត្រផង ហើយនិងលទ្ធិពុទ្ធសាសនាផងដែរ ។ ក្នុងករណីរបស់សម្ដេចសីហនុ យួនបាន«ទាញខ្សែញាក់» ម្ដងឲ្យស្ដេចឡើងជាវិរបុរស ដោយទាមទារឯករាជ្យពីបារាំង និងច្បាំងដេញទ័ពយៀកមិញ ចេញពីក្រចេះ ស្ទឹងត្រែង... ដោយគ្រាន់តែប្រើកាំភ្លើងឈើប៉ុណ្ណោះ, ម្ដងទៀតឲ្យស្ដេចងប់ងល់នៅក្រោមកន្ទុយក្បិនរបស់អ្នកម្នាងម៉ូនិក ឲ្យដើរតួក្នុងភាពយន្ត, ឲ្យចាប់បញ្ញាជនទៅបាញ់ប្រហារនៅត្រពាំងក្រឡឹង, ឲ្យទាត់ជំនួយអាមេរិកាំង និងឲ្យស្ដេចរត់ជាមួយអ្នកម្នាងទៅលើកទ័ពយៀកកុង មកវាយប្រហារស្រុកខ្លួនឯង ដើម្បីសមស្របនឹង«ពុទ្ធទំនាយ» ដែលយួនបានតាក់តែងពីបុព្វជាតិមកស្រាប់ «កាលណាប្រាសាទមាសប្រាសាទប្រាក់ផុសឡើងនៅទន្លេបួនមុខ (គឺសាលចតុមុខហើយនិងកាស៊ីណូ-១៩៧០) នឹងមានសឹកសង្គ្រាម ឈាមហូរដាបពោះដំរី ស្ដេចសតូចស្ដើងឡើងសោយរាជ្យនគរបី...» ។ សព្វថ្ងៃនេះ ស្ដេចសីហនុកំពុងតែឡើង សោយរាជ្យនៅលើ«នគរបី»ពិតមែន (!!) ។៚